ឧបករណ៏ភ្លេងដែលគេតែងតែលេងផ្សំជាមួយស្គរតូចមានដូចជាគង១៣ផ្លែ ឬគង៥ផ្លែ ដូចស្គរធំដែរ ។ គេវាយស្គរតូច ឱ្យត្រូវតាមសំឡេងគង ដើម្បីឱ្យអ្នកចូលរួមកម្មវិធីសែនមានការសប្បាយរីករាយ និងដើម្បីឱ្យអារក្សអ្នកតាដឹងឮ ហើយធ្វើឱ្យអ្នកភូមិរស់នៅសុខបានសុខដុមរមនា។

### ៦. សាគឺរ ប៉ាជូ / **ស្គរអារក្ស**

សាគឺរ ប៉ាជូ កា ឃឿង រ៉ត់ ម៉ោហ ម៉ោញ នៃវ ឡាក់ សុនសាត តំពួន គ្រឹង ព្រៅ ពិន អ្លូ ប្រ៉ត៍ លូ បាត់ យរ ឡឹង សើគ កេះ ហះកា ពូ យរ ផះ ពូ ប្រ៉ត៍ ប៉ាជូ តង៍ ប៉ាណ្លូស អីគ ព្លូ ។



**ស្គរអារក្ស** ជាឧបការណ៍ភ្លេងបុរាណ មួយប្រភេទ ដែលជនជាតិទំពួនគ្រឹង និងព្រៅ ចេះផលិត និងប្រើប្រាស់តាំងពីយូរលង់ណាស់មកហើយ តែគេប្រើបានតែពេលដែលគេបញ្ជាន់អារក្ស ។

### ៦.១.កាណាត៍ ពូ អ្យក់ ប្រ៉ត៍ សាគឺរ ប៉ាជូ / ធនធានដែលគេយកមកធ្វើស្គរអារក្ស

សាគឺរ ប៉ាជូ អា ពូ ម៉ាន លូ តេះ កាអ៊ិល អ៊ែ ទី ត្រង៍ ទ្រៀយ វ៉ឹច លូ គៀត សាតៃ (គៀត តឹស) អំពុ អ្លឹង អ៊ែ ឃឺ ប៉ែត ចឹង ទឹល ទងតិត៍ ម៉ិត ។ ចារ ពូ តាប៉ះ ពូ ប្រ៉ត៍ លូ អង់ការ រ៉ាយ៉ា លើ អង់ការ តាម៉ី ។ អ៊ែ ទី ព្លូ កាប្រហឹ តេះ ៧ កេះណោះ ពូ ច្រាត់ ដាត់ ឡាយ៉ាម័ ប្រ៉ែ ។ ហះ ឡាណុច អង់ការ ចារ ពូ សៃ៊ត ចាក់ លូ ប្រ៉ៃ ដាត់ ឡាយ៉ាម័ ដេល ខង ពូ ប៉ុច កា អ៊ែ កាចាប័ ។

ស្គរអារក្ស គេសូន្យអំពីដីឥដ្ឋ មានរាងដូចឃ្លោកធំ ហើយមានប្រវែងជិតកន្លះម៉ែត្រ បាតវាគេពាសនឹងស្បែកទន្សោង ឬស្បែកពស់ថ្លាន់ ។ វាមានពណ៌ប្រផេះរំលេចដោយក្បូរក្បាច់រចនាយ៉ាងស្អាត ។ នៅជាយស្បែកគេដេរភ្ជាប់នឹងតួស្គរ ដោយខ្សែផ្តៅយ៉ាងស្អាត ដើម្បីឱ្យវាជាប់បានយូរ ។

ឧបករណ៍ភ្លេងបុរាណ

## ៦.២.កាន យរ សាគឺរ ប៉ាជូ / ការប្រើប្រាស់ស្គរអារក្ស

ពូ យរ សាគឺរ ប៉ាជូ កាណុង កាន ប្រ៉គ័ ប៉ាជូ គ្រឹង ប៉ាជូ ព្រៅ៉ ប៉ាគ់ ស្រុក លើ ប៉ាគ់ ម៉ឺរ ។ ប៉ាណួស តាប៉ះ សាគឺរ ប៉ាជូ អា ទី ដឹង មួត កាម៉ាក័ ។ ពូ តាប៉ះ អ៊ែ អន់ឌូ លូ ប៉ា នឺរ ប៉ី ភឿ អន់ ប៉ាជូ យ៉ិល តាម ផ្លែង ម៉ោញ ៗ ។ ផះ ពូ តាប៉ះ សាគឺរ ណោះ ណាវ្គ ផា អ៊ែ តេះ អូ ត្រគ់ លូ ប៉ី ពូ តាទ្យេង ប៉ាអច់ សាគឺរ ពឹង អុញ ភឿ អន់ អង់ការ រ៉ឹត ថាំង ម៉ាគ់ ដាគ់ តេះ រ៉គ់ ។ រ៉ប់ដារ់ អា សាគឺរ ប៉ាជូ ហ្យូង អូ សូវ ទី ពូ ម៉ាន កេះ ខង កិ ញអៀ អូ សូវ ទី ប៉ាជូ ។

ស្គរអារក្ស គេប្រើបានតែក្នុងពិធីបញ្ជាន់អារក្សគ្រឹង ព្រៅ ដែលធ្វើឡើងនៅក្នុងភូមិ ឬនៅចំការ ។ ពិធីបញ្ជាន់អារក្សតម្រូវឱ្យគេទះស្គរ ផ្សំនឹងភ្លេងដទៃទៀត គេហៅថាប៉ី ដើម្បីឱ្យអារក្សច្រៀងត្រូវតាមលំដាប់លំដោយនៃបទនីមួយៗ ។ ពេលកំពុងលេងភ្លេងបើសំឡេងស្គរខុសពីសំឡេងប៉ី គេតែកំដៅបាតស្គរនឹងភ្លើង ដើម្បីឱ្យសំឡេងវាឮពីរោះដូចដើម ។ សព្វថ្ងៃនេះគេឡែងផលិតស្គរនេះទៀតហើយ ដោយសារមិនសូវមានអារក្ស ។

## ៧. ទ្រួ / គែន

កាណាគ័ អា  ឃឺ ឃឿង រ៉គ់ ម៉ោញ នែវ ណាវ្គ  ពូ អន់ សិច ផា ទ្រួ  ហះកា តំពួន ស្រុក អន់ដា អន់ សិច ផា ជើង  ស្រុក អន់ដា ណាវ្គ អន់ សិច ផា ដេង ។  សើគ ពៃ មួត តាតាម័ រ៉ូះ សុនសាត សួន ប៉ែត តំពួន គ្រឹង ព្រោ័ ឱុ យរ អ៊ែ ខាក់ ។

**គែន** ជាឧបករណ៍បុរាណមួយប្រភេទដែលជនជាតិទំពួនដាក់ឈ្មោះខុសៗគ្នាទៅតាមភូមិនីមួយៗ គឺភូមិខ្លះគេហៅថា **ទ្រួ** ភូមិខ្លះហៅថា **ជើង**  និងភូមិខ្លះទៀតហៅថា**ដេង** ។ កំលោះក្រមុំជំនាន់មុនៗចូលចិត្តប្រើវាណាស់ ។



## ៧.១.កាណាត័ ពូ អ្យក់ ប្រ៉ត័ ទ្រូ / ធនធានគេយកមកធ្វើគែន

ទ្រូ ពូ ប្រ៉គ័ លូ ប៉ាអ្ងូ លូ សាល្បៀវ ។ ឡាបៀប ប្រ៉គ័ ទ្រូ ឃឺ ពូ វែង ប៉ាអ្ងូ លើ សាល្បៀវ បក់ ពូ បាស ត្រគ់ ប៉ានីរ គួប អ៊ែ កេះ តគ័ អំប៉ាំង គួប អ៊ែ កេះណោះ វែង លើ កត់ ប៉ាតុំ គួប អ៊ែ កា ដាគ់ តាម បក់ ឡាប័ យរ ។ ទ្រូ ទី ប៉ានីរ ថាំង ថ្ងវ័ តគ់ អន់តគ់ ត្រគ់ អន់ដា ពូ ប្រ៉គ័ ដឹង ៧ កាតុ ត្រគ់ អន់ដា ណាវ្គ ៩ កាតុ អ៊ែ ទី ប៉ានីរ ម៉ង់ ទី ប៉ានីរ ម៉ោង លូ ទី ប៉ានីរ ថៃង ឡាក់កា គួង ទឹង នីទៅ ដេល ។ មួត ខ្លោម ទ្រូ អា សួន អៀង មួត អង់កាន់ រ៉ូះ ហះកា ពូ ខ្លោម មង កាម៉ាំង អន់ទ្រួល ឡឹង ពូ ចឹង តៃប សួន អៀង ពូ ខ្លោម អ៊ែ ប៉ាគ់ ស្រុក ។

គែនគេធ្វើអំពីឫស្សីផ្អរ ឬឫស្សីពកក៏បាន ។ វិធីធ្វើគឺគេវែងកំណាត់ឫស្សីដែលគេកាត់ត្រូវតាមខ្នង់សំឡេងរួចជាស្រេច បន្ទាប់មកវែងតម្រៀបគ្នា ឬចងភ្ជាប់គ្នាក៏បានអាស្រ័យតាមទម្លាប់អ្នកប្រើ ។ គែនមានសំឡេងតូច សំឡេងធំតាមលំដាប់រៀងគ្នា ដូចសំឡេងគងដែរ ។ អ្នកផ្លុំគែន ភាគច្រើនពួកក្រមុំៗ តែគេច្រើនផ្លុំនៅភូមិ នាពេលយប់មុនពេលចូលគេង ។

## ៧.២.ឡាបៀប ខ្លោម ទ្រូ / របៀបផ្លុំគែន

ទ្រូ ពូ ខ្លោម ប៉ាឡឹង ៗ ម៉ឹង ដឹង ខ្យាល ឡឹង ពីរ សាំរ៉ាប់ ប្រ៉គ័ អញ៉ូសែ ។ ម៉ៃគ តីទិ ញៀវ សាំរ៉ាប់ ប្រ៉គ័ ប៉ានីរ ម៉ង់ លូ ម៉ោង អន់ ត្រគ់ លូ យុ អញ៉ូសែ ។ ទ្រូ អា ពូ ខ្លោម ដឹង អ៊ែ កា ដាគ់ លើ ខ្លោម អន់ឌូ លូ ព្រួក លូ គួង ទឹង កា ដាគ់ ។

គេផ្លុំគែនដោយថ្ពម ហើយប្រើខ្យល់មាត់ធ្វើជាចង្វាក់ភ្លេង ។ មេដៃទាំងពីរសម្រាប់ធ្វើសំឡេងដូចគងម៉ង់ និងគងម៉ោង ។ គេផ្លុំវាតែឯងក៏បាន ឬផ្លុំផ្សំនឹងព្រួក ឬចាប៉ីឃ្លោកក៏បានដែរ។

## ៨. ព្រួក / **សាដៀវ**

កាណាគ័ អា សុនសាត តំពួន អើ សិច ផា ព្រួក អ៊ែ ទី ប៉ានីរ រ៉គ់ ណោះ ហាង ពូ សើគ ពែ ថៃ យរ អ៊ែ ឡាក់កា ឃឿង រ៉គ់ អន់ទៀគ ៧ ដេល ។

ឧបករណ៍នេះ ជនជាតិទំពួនហៅថា **ព្រួក** វាមានទឹកដមសំឡេងពីរោះ ទើបធ្វើឱ្យមនុស្សសម័យដើមនិយមប្រើប្រាស់វាណាស់ ។ វាមានរាងស្រដៀងនឹង **សាដៀវ** (ឧបករណ៍ភ្លេងខ្មែរ) ។



## ៨.១.កាណាត៌ ពូ អ្យក់ ប្រ៉ត៌ ព្រួក / ធនធានដែលគេយកមកធ្វើសាដៀវ

ទង ព្រួក ពូ ប្រ៉ត៌ លូ ប៉ាអូ តឹស តុ ម៉ែត តី តែង កាន់តេះ តូ លូ អ្លូង សាំរ៉ាប់ ចារ គែត កាសែ ។ ព្រួក ទី កាសែ ២ ពូ ប្រ៉ត៌ លូ កាសែ ឡោះ កាសែ ម៉ោញ សាំរ៉ាប់ ថាំង កាសែ ម៉ោញ ណាវ្គ សាំរ៉ាប់ ថូវ័ ។ តុះ អ៊ែ ៥ កាតុ ពូ ប្រ៉ត៌ លូ សាលៀ វ៉ាំងគួង ប៉ឹត លូ ទូត តុទ កាចាប័ ។ ប៉ាណង់ ពៀវ ពូ ប្រ៉ត៌ លូ ប៉ាអូ កាពឹល ត្រាង័ ៧ កា ដាគ់ លូ អ្លូង កា ដាគ់ ។ ភឿ ជែ អន់ ឡាកាញ៉ូ តី បក់ អន់ទែង ព្រួក ពូ ចៃគ អន់តួវ ហះ អន់តិត៌ លូ អន់ អ៊ែ តេះ សាដាល់ ។

តួសាដៀវ ធ្វើពីដើមឬស្សីទំហំប៉ុនមេដៃ និងឈើមួយកំណាត់ សំរាប់ធ្វើមេទប់ខ្សែ ។ វាមានខ្សែពីរធ្វើអំពីអំបោះ ខ្សែមួយសំឡេងតូច ហើយខ្សែមួយទៀតសំឡេងធំ ។ រីឯខ្ទង់សំឡេងទាំងប្រាំរបស់វា គេធ្វើអំពីពកពុទ្រាព្រៃ បិទភ្ជាប់ដោយជ័រម្រោមយ៉ាងជាប់ ។ ព្រលួតទាំងពីសម្រាប់រឹតខ្សែ គេធ្វើអីរឬស្សីចាស់ហើយក្រាស់ល្អ ឬធ្វើអំពីឈើក៏បាន ។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកលេងកុំឱ្យចុកដៃ និងមាន សំឡេងឮខ្លាំងគេបានដាក់ឃ្លោកមួយចំ ចំនុចកណ្ដាលតួរបស់វា ។

## ៨.២.កាន យរ ព្រួក / ការប្រើប្រាស់សាដៀវ

មួត បក់ អ្លូ អន់ទែង ព្រួក អា ឃី ទី ដឹង មួត កាម៉ាក័ ៧ ។ មួត តាតាម័ ឌុ អន់ទែង ព្រួក អា ផះ អន៉ខ៊ែ អ្វៃ ប៉ាតុំ គួប ពឹង រ៉ោង លូ ប៉ាគ់ រ៉ោង ដង់ ចារ អន់ខ៊ែ តៃប លូ ប៉ាគ់ ហី មួត អង់កាន់ រ៉ូះ ។ តាតាម័ ពូ សើគ ពៃ អ្លូ អញ់សៃ អន់ទែង ព្រួក អៀង ឡាក់កា អញ់សៃ ប្រ៉ុ អង់កាន់ បើក អំប៉ារ ប្រ៉ុ ត្រាក័ ពេល អញ់សៃ ចាក់ ទឹង គង លូ អញ់សៃ ចាវ៉ៃ ។ ហះកា សុនសាត ទំពួន អន់ទែង ព្រួក អា អន់ឌូ លូ កាណើ សាំរ៉ាប់ ប្រ៉ែគ័ ប៉ាជូ ទំពួន ។ មួត បក់ អ្លូ អន់ទែង ព្រួក អញ់សៃ ប៉ាជូ ទី ដឹង មួត កាម៉ាក័ ក្រាគ់ ។

អ្នកដែលចេះលេងសាដៀវនេះ គឺមានតែបុរសៗតែប៉ុណ្ណោះ ។ ពួកកំលោះៗ ចូលចិត្តដេញសាដៀវ នៅកន្លែងដែលគេជួបជុំគ្នា ដូចជានៅរោងភូមិ នៅផ្ទះកូនកំលោះ និងនៅផ្ទះកូនក្រមុំ ដើម្បីស្ដាប់កំសាន្ត និងបង្កើនភាពស្និទ្ធស្នាល ។ កំលោះពីដើមចេះបទច្រើនសម្រាប់ដេញដូចជាបទ សុំនាងបើកទ្វារ សុំនាងក្រាលកន្ទេល ចាក់ទឹងគង និងបទសៃមចាវ៉ៃជាដើម ។ ក្រៅពីការដេញសម្រាប់ស្ដាប់កំសាន្ត ជនជាតិទំពួនដេញសាដៀវផ្សំនឹងភ្លេងកាណើពេលណាគេធ្វើពិធីបញ្ជាន់អារក្សទំពួន ។ ប៉ុន្តែអ្នកដែលចេះដេញចង្វាក់ភ្លេងអារក្សនោះ មានតែបុរសចាស់ៗប៉ុណ្ណោះ ។

## ៩. កាណី / កាណី

កាណិ អា  ឃឺ ឃឿង វ៉ត់ ម៉ោញ នែវ  សុនសាត តំពួន ប្រ៉ត័ សាំរ៉ាប់ អ៊ិត អញ់សែ៊ ម៉ោហ លូ អញ់សែ៊ ប៉ាជូ  តំពួន ។  អ៊ែ ទី ប៉ានីវ វ៉ត់ វ៉ែ ខាក់  ហះកា អ្វ សូវ សាដាល់ ប៉ុប ចំ អុះ ។

ឧបករណ៍ភ្លេងនេះ ជនជាតិទំពួនហៅថា **កាណី ។** វាឧបករណ៍ភ្លេងមួយប្រភេទដែលជនជាតិទំពួនផលិតឡើងសម្រាប់លេងបទបុរាណ ចម្រៀងបុរាណ ឬចម្រៀងអារក្សទំពួន ។ វាមានទឹកដមសំឡេងពីរោះណាស់ តែវាមិនសូវខ្លាំងទេ ។



## ៩.១.កាណាត័ ពូ អ្យក់ ប្រ៉ត័ កាណើ / ធនធានដែលគេយកមកធ្វើកាណើ

ភ្លូង ពូ ឌុ អ្យក់ ប្រ៉ត័ កាណើ ឃឺ តើម  ច្បុះ ខង អ៊ែ ប្រ៉ត័ អន់ កាណើ តេះ វ៉ក់ លូ ដាគ់ អូ ចាដះ តិគ័ ។  កាណើ អា ត្រង័ អ៊ែ ឡាត ពឹង អន់ទិ អ៊ែ ពូ ច្រាគ់ ដាគ់ ឡាយ៉ាម័ ខាក់ ។ អ៊ែ ទី តុះ ៩ ឡាក់ កា ព្រួក ដេល ។  ភឿ ជែ អន់ ឡាកាញ៉ូ តី បក់ អ៊ិត លូ អន់ អ៊ែ តេះ ឡាហាង ពូ ចៃគ អន់តួវ គៀត ហះ អន់តិគ័។  មួត បក់ អ្លុ អ៊ិត កាណើ អា ឃឺ ទី ដឹង មួត កាម៉ាក័ ៧ ។

ដើមឈើ ដែលគេនិយមយកមកធ្វើជាកាណើគឺដើម **ច្បុះ** ព្រោះវាធ្វើឱ្យកាណើ ឮល្អ និងមិនប្រេះបែកទៀតផង ។ វាមានរាងសំប៉ែត រំលេចទៅដោយក្បូរក្បាច់រចនាយ៉ាងស្អាត ។ វាមានខ្ទង់ចាប់សំឡេងចំនួន៩ ដូចសាដៀវដែរ ។  ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកលេងកុំឱ្យចុកដៃ និងមានសំឡេងខ្លាំងល្អ គេបានដាក់ឃ្លោកមួយចំកណ្តាលតួរបស់វាដម្រាប់ផ្ទឹបនឹងដើមទ្រូងពេលណាគេកូតវា ។ អ្នកដែលចេះកូតកាណើ គឺមានតែបុរសៗតែប៉ុណ្ណោះ ។



ឧបករណ៍ភ្លេងបុរាណ

## ៩.២.កាន យរ កាណី / ការប្រើប្រាស់កាណី

**កណី** ពូ ប្រ៉ែគ័ សាំរ៉ាប់ អ៊ិត កា ប៉ាជូ ទំពួន ។ ផា ពូ អ្យក់ ប៉ាជូ ម៉ោញ ទង ៗ ពូ អ៊ិត កាណី ឡឹង តើម ង៉ាច ទឹល តារ សាំបួត់ ឡូត ខង ប៉ាជូ ទី ផ្លែង អៀង ខាក់ ។ ប៉ាណូស អ៊ិត កាណី ត្រគ់ អ៊ិត ប៉ាណាំ ផ្លែង ប៉ាជូ អន់ទ្រួល ឡឹង ព្រួក កេះណោះ ប៉ាជូ យ៉ិល ពួយ អន់តឹគ ។ ប៉ាណូស បក់ អ្លុ អ៊ិត កាណី អន់ខ្មែ អ្លុ យុ អញ៉ូសែ អៀង ណោះ អន់ខ្មែ ចឹង អ្លុ ប៉ាណាំ ទ្រង ប៉ាជូ ។

កាណីត្រូវបានគេផលិតសម្រាប់កូតក្នុងពិធីបញ្ជាន់អារក្សទំពួន ។ ដូចនេះពេលគេបញ្ជាន់អារក្សទំពួនម្ដងៗគេកូតកាណីនេះតាំងពីក្បាលព្រលប់រហូតដល់ភ្លឺ ព្រោះអារក្សមានទំនុកច្រៀងច្រើនណាស់ ។ អ្នកកូតកាណីត្រូវកូតនាំមុខអារក្សជានិច្ចមុនសាដៀវ បន្ទាប់មកអារក្សច្រៀងតាមក្រោយ ។ អ្នកដែលចេះកូតកាណី គឺជាអ្នកដែលចេះបទភ្លេងអារក្ស ។

ដាក់រូបភាពកូតកាណី

ឧបករណ៍ភ្លេងបុរាណ

## ១០. ម៉ុម / ទ្រ

**ម៉ុម** ឡាក់ ឃឿង រ៉ត់ ម៉ោញ នៃវ ត្រង័ អ៊ែ ចឹង រ៉ិច លូ ព្រួក ហះកា អ៊ែ ទី កាសែ៊ ដឹង ម៉ោញ លូ ទី ទឹង សាំរ៉ាប់ អន់ តេះ កត់ លូ កាសែ៊ ព្រៀយ តុត ថាំង ភឿ អន់ អ៊ែ តេះ ចាដាល់ កេះ ណោះ ពូ អ៊ិត អ៊ែ អញ់សែ៊ សើត ពៃ កា អ្លុ អញ់សែ៊ កិញអៀ កា អ្លុ ដេល ។



ទ្រ ជាឧបករណ៍ភ្លេងមួយប្រភេទទៀត ដែលមានរូបរាង ស្រដៀងនឹងព្រួកដែរ ប៉ុន្តែវាមានខ្សែតែមួយ និងបំពង់សំឡេងមួយភ្ជាប់ដោយខ្សែអំបោះយ៉ាងតឹង ដើម្បីឱ្យវាមាន សំឡេងឮខ្លាំងរំពង ហើយកូតបានទាំងបទសម័យទាំងបទបុរាណ ។ ចំពោះសំឡេងវាវិញ ឮសូរពិរោះគួរឱ្យចង់ស្តាប់ ។

## ១០.១.កាណាត័ ពូ អៀក់ ប្រ៉ត័ ម៉ុម / ធនធានដែលគេយកមកធ្វើទ្រ

កាណាត័ ពូ អៀក់ ប្រ៉ត័ ម៉ុម កា អូ យច ឡឹង កាណាត័ ពូ អៀក់ ប្រ៉ត័ ព្រួក អុះ ទី ប៉ាអូ អ្លីង លូ សាល្បៀ សាំរ៉ាប់ ប្រ៉ត័ តុះ ឡាក់ ចារ តួរ័ ប៉ានីរ ថូរ័ លើ ថាំង ហះកា ម៉ុម ពូ ចៃគ កាសែ៊ ដឹង ម៉ោញ សាំរ៉ាប់ អ៊ិត ។

ធនធានដែលគេនិយមយកមកធ្វើទ្រ ក៏មិនខុសពីសាដៀវនោះទេ គឺមានឫស្សី ឈើ និងបន្ទារធំៗសម្រាប់បិទភ្ជាប់ធ្វើខ្ចង់សំឡេង គ្រាន់តែទ្រគេដាក់ខ្សែតែមួយសម្រាប់កូត ។

ឧបករណ៍ភ្លេងបុរាណ

## ១០.២.កាន  យរ ម៉ិម / ការប្រើប្រាស់ទ្រ

ម៉ិម ឃី ឃឿង រ៉ត់ ម៉ោញ នែវ ទី ប៉ានីរ រ៉ត់ ខាក់ សួន អៀង ពូ អ៊ិត អ៊ែ អន់ឌូ លូ គួង ទឹង លើ គួង ថៃង ភឿ តង័ មួត ប្រ៉ត័ អញ់ស៊ែ អន់ ត្រត់ ពួយ ប៉ានីរ គួង បក់ ពូ អ្វៃ ចំ ភឿ ដែ អន់ ប៉ាល្ងួស យ៉ិល ពឹក លើ ប្រ៉ាល់ តាឡាម័ ។  មួត ឌុ អ៊ិត ម៉ិម សួន អៀង មួត តាតាម័    អន់ឌ្មៃ បាត់ អ៊ិត កាណុង រ៉ោង មង កាម៉ាំង ។ ចានែក មួត ក្រាត់ មួត សាណាដី អន់ឌ្មៃ យរ ម៉ិម ដារ់ ចំ ទី កាន កាតាប័ ចំ គួង អញ់ស៊ែ ស៊ិនឡាប៉ាត់ ។ ពូ អ៊ិត ម៉ិម យុ អញ់ស៊ែ ចំហូ កា អ្លុ  លូ អញ់ស៊ែ ស៊ិនឡាប៉ាត់ កា អ្លុ ដេល ។

ទ្រក៏ជាឧបករណ៍ភ្លេងដែលមានទឹកដមសំឡេងពីរោះមិនចាញ់ភ្លេងដទៃឡើយ ភាគច្រើនគេកូតវាផ្សំជាមួយចាប៉ីឃ្លោក និងគង១២ផ្លែ ដើម្បីបង្កលក្ខណៈងាយ ស្រួលដល់អ្នកច្រៀង ឱ្យច្រៀងត្រូវតាមចង្វាក់ ។ អ្នកដែលប្រើឧបករណ៍ភ្លេងទ្រច្រើនជាងគេគឺកំលោះៗ ជាពិសេសគេចូលចិត្តលេងនៅរោងភូមិនាពេលយប់ ។ ឯចាស់ៗគេប្រើតែពេលណាមានកម្មវិធីសិល្បៈរាំគង តែប៉ុណ្ណោះ ។



## ១៦. គួងទឹង / ចាប៉ីឃ្លោក

គួង ទឹង អា កា ឃឿង រ័គ់ ម៉ោញ នៃវ ពូ ឌុ យរ ឡឹង ប៉ាសើគ នីទៅ ដេល ហះ កា ពូ យរ ក្លឹង កាខាក់ ផះ រ៉ាំងរ៉ាំង សាណាំ ១៩៧៩ ទឹល ១៩៩៣ ខង រ៉ាំងរ៉ាំង ណោះ ពូ ឌុ ថត អញ់សែ ចំហូ តំពួន ញូន កា ទី ពូ អ្ន ប្រ៉ែត៍ អញ់សែ ចំហូ អៀង ដូវ ។ មួត បក់ អ្ន ចំ គួងទឹង ឡាក់ លៅ សិច ឡឹង ពូ ទី ឡាក់ កា វត័ កាឌិត វត័ ដាយ វត័ ខ្យុង វត័ រ៉ូ ទី អៀង ឡឹងណោះ ណាវ្គ ។ រ៉ាំងរ៉ាំង សាណាំ ១៩៨៣ ទឹល ១៩៩៣ អូ ផា កា កាណុង ស្រុក អូ ផា កា ប៉ាត់ ចារ តាហាន អូ ផា កា ប៉ាត់ ចារ មួត កុម៉ា ហៀន ឃឺ ទី គួង ទឹង ទិ ណោះ៍ ។

**ចាប៉ីឃ្លោក** ជាឧបករណ៍ភ្លេង ដែលបុរសជនជាតិដើមភាគតិច និយមប្រើ ច្រើន ដូចភ្លេងដទៃទៀតដែរ ជាពិសេសក្រោយឆ្នាំ១៩៧៩-១៩៩៣ ព្រោះក្នុង កំឡុងឆ្នាំនោះ គេនិយមថតចំរៀងចំហូភាសាទំពួន ដែលច្រៀងដោយអ្នកចំរៀង ល្បីៗជាច្រើនរូប ។ តន្ត្រីករចាប៉ីឃ្លោកជើងចាស់លេចធ្លោជាងគេមានលោក កាឌិត លោក ដាយ លោក ខ្យុង លោក រ៉ូ លោក ចាង ជាដើម ។ល។ ចន្លោះឆ្នាំ១៩៨៣-១៩៩៣ ទាំងនៅក្នុងភូមិ ទាំងនៅបន្ទាយទាហាន ឬនៅមណ្ឌលកុមារឈានមុខ ដែលមានបងប្អូនជនជាតិដើមភាគតិចច្រើនគឺតែងតែមានវត្តមានចាប៉ីឃ្លោកនៅទីនោះ ។



**១១.១.កាណាត៍ ពូ អ្យក់ ប្រ៊ត៍ តួង ទឹង** / **ធនធានដែលគេយកមកធ្វើចាប៉ីឃ្លោក**

-ប៉ាអូ  លើ សាល្បៀវ ម៉ោញ អង់វ៉ាន  សាំរ៉ាប់ ប្រ៊ត៍ ត្រង់

-អន់ទ្រៀម ចំលួន  ១០ កាសៃ សាំរ៉ាប់ ។

-គៀត សាំរ៉ាប់ បាល ប្រ៊ត៍ អន់តួវ  អន់ អ៊ែ ហោល

-គង សាំរ៉ាប់ ខើយ្ហ អន់ទ្រៀម ជៃ អន់ អ៊ែ ទឹះ ទឹង

-ប៉ាអូ ត្រាង៍ ៧ លើ អ្លួង សារ សាំរ៉ាប់ ប្រ៊ត៍ ប៉ាណង់

-ឫស្សីផ្អរ ឬ ឫស្សីពកមួយកំណាត់សម្រាប់ធ្វើតួររបស់ចាប៉ីឃ្លោក

-លួសចំនួន ១០ខ្សែ

-ឃ្លោកសម្រាប់ចងភ្ជាប់នឹងតួចាប៉ីឃ្លោក ដើម្បីឱ្យសំឡេងវាឮខ្លាំង

-កងធ្វើពីដែក ឬស្ពាន់ សម្រាប់កល់ខ្សែសំឡេងកុំឱ្យវាទើសនឹងបំពង់ឫស្សី ។

-ឫស្សីចាស់ហើយក្រាស់ ឈើខ្លឹម សម្រាប់ធ្វើព្រលួត

## ១១.២.កាន យរ គួង ទឹង / ការប្រើប្រាស់ចាប៉ីឃ្លោក

គួង ទឹង ពូ ប្រ៉ែគ័ សាំរ៉ាប់ កាប្លេះ ប៉ិច កា រ៉ែគ់ សើម ពុត ព្យេក ។ ចានែក មួត តាតាម័ ៗ អន់ឌ្ហែ អ្យក់ គួង ទឹង ឡាំ កាប្លេះ ប៉ាគ់ ហី មួត អង់កាន់ រ៉ូះ អង់កាន់ ដាយ មង កាមុាំង ។ ត្រគ់ អន់ដា អន់ឌ្ហែ យ៉ិល តើល សឹត តើល ប៉ានីរ សោប កា ទី ដេល ។ គួង ទឹង ទី ប៉ានីរ ឡាក់កា គួង ដោច ដេល កេះណោះ ណាវ្គ ពូ កាប្លេះ អញ់សែ៊ ណើរ ណាវ កិញអ្យៀ កា អ្លូ អញ់សែ៊ សើគ កា អ្លូ ដេល តាម បក់ អ្យះ ។ ផា ពូ កាប្លេះ ម៉ោញ ទង ៧ ពិន សាំយ៉ាំង រ៉ែគ់ អ្រែះ កាញ់អ្រែះ លូ ឡាម៉ែគ់ ពួយ ប៉ានីរ ពូ យ៉ិល ខង ប៉ាណួស កាប្លេះ ទី ដឹង ១ដូវ ។ គួង ទឹង អា ពូ ខ្លេះ ដឹង អ៊ែ ង៉ាត កា ដាគ់ ខ្លេះ អន់ឌូ លូ ទ្រួ មុិម កា ដាគ់ ។

គេធ្វើចាប៉ីឃ្លោកសម្រាប់ដេញកំសាន្តអារម្មណ៍ពេលអផ្សុក ។ ហើយចំណែកពួកកំលោះៗ គេដេញចាប៉ីឃ្លោកនៅពេលណាដែលគេនៅជុំគ្នានៅរោងប្រជុំភូមិ និងនៅផ្ទះកូនក្រមុំនៅពេលយប់ព្រលប់ ។ ពេលខ្លះកំលោះ និងក្រមុំ ច្រៀងឆ្លើយឆ្លងគ្នាក៏មានដែរ ។

លក្ខណៈពិសេសរបស់ចាប៉ីឃ្លោក គឺវាមានប្រព័ន្ធសំឡេងដូចគងធំដែរ ប៉ុន្តែគេដេញបានទាំងបទសម័យ និងបទភ្លេងគងបុរាណ អាស្រ័យលើការប៉ិនប្រសប់របស់តន្ត្រីករ ។ លើស ពីនេះទៀតសោត វាមានសំឡេងពិរោះរង្គំ ហើយអាចលើកដាក់សំឡេងតាមអ្នកច្រៀងបានយ៉ាងងាយ ព្រោះអ្នកដេញមានតែម្នាក់ ។ គេដេញចាប៉ីឃ្លោកដាច់តែឯងក៏បាន ឬដេញប្រគុំជាមួយភ្លេងដទៃទៀតដូចជា ទ្រ គែន ក៏បាន ។





## ១២. ចៃង តាឡោង / គងឃ្មោះ

**ចៃង តាឡោង** ឃឺ ឃឿង វ៉ត់ ម៉ោញ នៃវ ទីត្រង័ វ៉ឺល ឡាក់កា គួង ចៃង ដេល ហះកា អ៊ែ តឹស ថិ សាម៉ុី ទៅ គួប អ៊ែ ។ ពូ ចំ អ៊ែ ពេល ទី កាន អៃត សង់ អន់ទ្យេត ៗ ឡាក់កា អៃត សៃន ស្រុក អៃត ប្រ៉េគ័ ប្រ៉េះ ហឹ អៃត ប៉ាញ៉សង់ អៃត អ្យក់ សឹត ក្លោ កម៉ាញ៉ អៃត ប្រ៉េគ័ ប្រ៉េះ ប៉ាគ់ ម៉ុីរ អន់ដា ដេល ។

ឃ្មោះ ជាឧបករណ៍ភ្លេងម៉្យាង មានរាងមូលដូចគងដែរ តែមានចំនួន១គូ និងមានទំហំប៉ុនគ្នា ។ ឃ្មោះគេវាយក្នុងពិធីផ្សេងៗដូចជា សែនភូមិ សែនតាមគ្រួសារ រៀបការ ផ្លាស់ទីលំនៅ និងពិធីសែនចំការជាដើម ។



## ១២.១.ចារ ពូ តាច់ ចែង តាឡោង / ប្រភពដែលគេទិញគងឃ្មោះ

មួត ក្រាគ់ ៧ រ៉ះ ផា ចែង តាឡោង អា ពូ តាច់ ឡឹង ប៉ាថេត ឡាវ កាំឡៃ កាប៉ូវ ៧ កល់ លើ ១៥ កល់ លើ អៀង ឡឹង អា កា ទី ដេល ។ ទី ដឹង ក្រាគ់ ស្រុក លូ បក់ ប្រ៉ះ ប៉ាត្រង័ ទី កាប៉ូវ រ៉ក់ អៀង ចឹង ទី តាច់ ចែង តាឡោង អា ។ ចែង តាឡោង ឡាក់ ពូ យើយ តាច់ យរ ទី ២ នៃវ នៃវ ទី ១ ពូ ប្រ៉គ័ លូ ប៉ាសយ់ នៃវ ទី ២ ពូ ប្រ៉គ័ លូ សាប៉ាន័ ។ ចែង តាឡោង គឹត ខា ឡឹង ពូ ឃឺ ចែង តាឡោង ទី ឡាយ ជៀត ម៉ាស ជៀត សាំរ៉ុត ។

តាមចាស់ៗនិយាយប្រាប់ គងឃ្មោះមួយគូរ គេដូរនឹងក្របីពី៧-១៥ ក្បាល ឬអាចច្រើនជាងនេះ ក៏មានដែរ ។ មានតែមេកន្រ្ទាញ និងអ្នកមានឥទ្ធិពល ដែលមានទ្រព្យសម្បត្តិ គោក្របីច្រើនទេ ទើបមានលទ្ធភាព ទិញគងឃ្មោះនេះបាន ។ គងឃ្មោះ ដែលគេធ្លាប់ទិញយកមកប្រើប្រាស់មានពីរប្រភេទ គឺគងឃ្មោះធ្វើអំពីដែក និងគងឃ្មោះធ្វើអំពីស្ពាន់ ។ ហើយគងឃ្មោះដែលថ្លៃជាងគេ គឺគងឃ្មោះណាដែលមានលាយជាតិមាស និងជាតិសំរិទ្ធ ។

## ១២.២.ឡាបៀប ចំ ចៃង តាឡោង / របៀប វាយគងឃ្មោះ

ចៃង តាឡោង អា ពូ តង កាន ប៉ាណូស ២ លើ ៣ ដូវ សាំរ៉ាប់ ចំ អ៊ែ ឃី គែង ង៉ឺរ ១ ដូវ គែង អង់កក់ ១ ដូវ លើ ២ ដូវ កា ដាត់ ។ មួត បក់ អ្លួ ចំ ចៃង តាឡោង អា ទី ដឹង មួត តាំងកង់ ក្រាត់ ។ យុ ពូ ចំ ចៃង តាឡោង អា ទី អ្វូ ប៉ៃត អុះ ។ ពូ ចំ អ៊ែ ប៉ាតាង ប៉ានីរ កាប ឡាក់កា កាប ប៉ានេ តាំប៉ោក គួប សោប លើ តះ រ៉ល់ ញួក ទ្យុំ គួប សោប ប៉ាអប់ ពឹង ពឹង ណោះ ហង ភឿង អន់ ទី កាន រ៉គ់ សើម ។

ក្នុងការវាយគងឃ្មោះ គឺគេត្រូវការមនុស្សពី២ទៅ៣នាក់ គឺខាងមុខ ១នាក់ ឯខាងក្រោយ១នាក់ក៏បាន ២នាក់ក៏បាន ។ អ្នកដែលចេះវាយ គឺមានតែបុរសចាស់ៗ ។ ទំនុកបទដែលគេវាយឃ្មោះមានច្រើនប្រភេទ ។ ហើយអត្ថន័យក្នុងបទនីមួយៗនោះ គឺមានការសរសើរ បង្អាប់ ឬលេបខាយគ្នាទៅវិញទៅមក ដើម្បីបង្ករភាពសប្បាយរីករាយ ។



## ១៣.ប៉ី / ប៉ី

ប៉ី ឃី ឃឿង រ៉ត់ ម៉ោញ នែវ ពូ ប្រ៉ត័ សាំរ៉ាប់ ខ្លោម អន់ឌូ លូ សាគឺរ ផះ ពូ ប្រ៉ត័ ប៉ាជូ ត្រឹង លើ ប៉ាជូ ព្រ៉ា ។ ប៉ានីរ ប៉ី រ៉ត់ នីទៅ ដេល ដឹង កា អ៉ែ តេះ ប្រ៉ត័ កាន់ខ្មែល ៧ ប៉ែត ។ អ៉ែ ទី ត្រោម សាំរ៉ាប់ ពុត ប៉ាហើយ ប៉ានីរ ចំលួន តាំប៉ើះ ត្រោម ឡាក់កា ច្បាប់ ដេល ។

ប៉ីជាឧបករណ៏ភ្លេង សម្រាប់ផ្លុំផ្សំជាមួយនឹងស្គរ ពេលណា មានកម្មវិធីបញ្ជាន់អារក្សត្រឹង និងអារក្សព្រៅ ។ ប៉ីមានសំឡេងពីរោះ តែវាពុមិនសូវខ្លាំងទេ ។ វាមានរន្ធខ្ទង់សំឡេងចំនួន ៧រន្ធដូចខ្លុយដែរ ។



## ១៣.១.កាណាត័ ពួ អ្យក់ ប្រ៉ត័ ប៉ី / ធនធានដែលគេយកមកធ្វើប៉ី

កាណាត័ ពូ អ្យក់ ប្រ៉ត័ លូ ប៉ាអូ លើ សាល្បៀវ ត្រាង័ ៧ តីស តុ ម៉ៃគ តី ។ ទ្រង កាំប៉ុង ពូ ចាវ គ្រោម សាំរ៉ាប់ អន់ ទី ប៉ានីរ ថូវ័ ថាំង ចំលួន ៦ គ្រោម ។ ទ្រង កាន់ តេះ ពូ ចាវ ១ គ្រោម ។ ចអំប៉្បិត អ៉ែ ពូ ប្រ៉ត័ លូ សាប៉ាន័ ប្រ៉ាក់ ចៃគ ប៊ិង ចានែង គែង សាំងអេ្យា ។ ប៉ុ ទី អំពុ អ្លឹង ឃឹ ១ហាត់ ។

ធនធានដែលគេយកមកធ្វើប៉ីមាន ឫស្សីផ្ករ ឬ ឫស្សីពកដែលចាស់ល្អ ហើយមានទំហំប៉ុនមេដៃ ។ ផ្នែកខាងលើគេចោះរន្ធសម្រាប់ធ្វើខ្ទង់សំឡេងចំនួន ៦រន្ធ ហើយផ្នែកខាងក្រោមគេចោះរន្ធតែ១រន្ធប៉ុណ្ណោះ ។ឯអណ្ដាតរបស់វាគេធ្វើពីស្ពាន់ ឬប្រាក់ ហើយគេចោះកន្លែងដាក់វានៅចំហៀងខាងឆ្វេង ។ ប៉ីមានប្រវែងប្រហែល១ហត្ថ ឬក្រោមកន្លះម៉ែត្រ ។



អំប្បិត / អណ្ដាត

តែង កល់ / ផ្នែកក្បាលនៃប៉ី






គ្រោម កាន់តេះ / រន្ធខាងក្រោម

## ១៤.គួង ណាគ់ / រនាត

គួង ណាគ័ ឃី ឃឿង វ៉ត់ ម៉ោហ ម៉ោញ នៃវ សុនសាត សួន ប៉ែត តំពួន គ្រឹង ព្រៅ ប្រ៉េគ័ សាំរ៉ាប់ ចំ ប៉ាតាង គួង ដោច ឡាក់កា គួង ទឹង នីទៅ ដេល អ៉ែ ទី ប៉ានីរ វ៉ត់ លូ ដាត់ ឡាហាង ណើង តិគ័ ។ ពូ ឌុ ចំ គួង ណាគ់ ផះ ពូ អ៉្វៃ ប៉ាគ់ ម៊ុរ ម៉ោញ ដូវ ម៉ោញ ឌ៉ែន លើ ប៉ាគ់ ចារ ពូ រង កាប៉ូវ វ៉ក់ ភ្យឿ ជែ អន់ ឡាង៉ាន់ ។

រនាត ជាឧបករណ៏ភ្លេងបុរាណ មួយបែបទៀត ដែលជនជាតិទំពួន គ្រឹង ព្រៅ ផលិតឡើងសម្រាប់វាយជំនួសគងធំដូចចាប៉ីឃ្លោកដែរ វាមានទឹកដមសំឡេងពីរោះ ហើយឮខ្លាំងទៀតផង ។ គេចូលចិត្តវាយរនាត ពេលណាគេនៅចំការម្នាក់ឯង ឬនៅកន្លែងឃ្វាលគោ ក្របី ដំរី ដើម្បីកំសាន្តអារម្មណអផ្សុក ។



ហ៊ូប វត៌ ក្រាគ់ ច៌ គួង ណាគ់

## ១៤.១.កាណាគ័ ពូ អ្យក់ ប្រ៉ែគ័ គួង ណាគ់ / ធនធានដែលគេយកមកធ្វើរនាត

គួង ណាគ់ ពូ ប្រ៉ែគ័ លូ ប៉ាអ្វូ លើ សាល្យេវ ត្រាង័ ៧ ចំលួន តាំងហាម តាឡ្វត់ ។ ឡាប្យេប ប្រ៉ែគ័ ឃឺ ពូ កាព្រែល ប៉ាអ្វូ / សាល្យេវ ទី អំពុ អ្លឹង ទងតិគ័ មិត អន់ ជឺរ ហះកា ពូ ត្រគ់ កាព្រែល អន់ អ្លេះ ឡឹង គួង អ៊ែ តគ់ អន់តគ់ កេះណោះ ពូ បាស ប្រ៉ែគ័ កាស៊ែ ប៉ានឺរ ។ កេះណោះ ណាវ្គ ពូ តគ័ អន់សាម៉ើ ទៅ គួប អ៊ែ ទ្រេវ្យក កេះណោះ វ៉ែង លូ កាស៊ែ ដាគ់ ៧ ភឿ ជែ អន់ អ៊ែ តាពល រ៉ីវ៉ាច័ ប៉ាគ់ ពូ ចំ ម៉ោញ ទង ៧ ។

រនាត ជាឧបករណ៍ភ្លេងបុរាណ គេផលិតអំពីឫស្សីផ្អរ ឬ ឫស្សីពក ដែលចាស់ល្អចំនួន៨កង់ ។ របៀបធ្វើ គឺកាត់ឫស្សីជាកង់ៗប្រវែងប្រហែលកន្លះម៉ែត្រចុះក្រោម ធ្វើយ៉ាងណាឱ្យវាមានរវៀងខ្លីជាងគ្នាជាបន្តបន្ទាប់ រួចគេចាប់ផ្តើមកាត់ចេញប្រហែលពាក់កណ្តាលនៃមុខកាត់ ដើម្បីធ្វើខ្ទង់សំឡេង ។ បន្ទាប់មកគេតម្រៀបតាមលេខរៀង រួចវ៉ែងយ៉ាងជាប់ល្អ ដើម្បីកុំឱ្យខ្ទាត ឬរបូតចេញពេលគេវាយម្តងៗ ។

## ១៥. ទិង ទូត / ទិងទូត

**ទិង ទូត** ឃី យឿង វ៉ត់ ម៉ះ ពូ សើគ ពៃ ឡាក់ ឡាម៉ត់ ប្រ៉គ័ ក្វា ឡឹង ពូ ក្រាន័ កា អ្យក់ ប៉ាអូ លើ សាលៀវ ម៉ោញ អង់វ៉ាន កេះណោះ កាសិត ឡាច់ អង់កោស តែង គុល តែង ក្យង់ លូ តាំប្រឹល អន់ សាម៉ើ កេះ ហង ។ ទឹង ទូត ពូ តាប៉ះ មង កាម៉ាំង ព៉ាំងវ៉ាំង ខៃ **រកតីស** ទឹល ខៃ **សប់** ខង ខៃ ណោះ ពៀ ស្រ៊ស ឡាក់ កា ពៀ កាញ់ជៃ ពៀ ក្រែង លូ ពៀ កាវែត ត្រត់ ទុំ ហង ។ ផា ហ្វាស ឡឹង ខៃ ពៀរ ៧ អា ពូ អូ តាប៉ះ ទឹង ទូត កេះ ខង អ្យូគ កា បិក កាប់ ។ យុ ពូ តាប៉ះ ទឹង ទូត ទី ពៀរ នៃវ : ឃី នៃវ ពឹក លូ យុ នៃវ ប្រ៉ាល់

**ទិងទូត** ជាឧបករណ៍ភ្លេងដែលងាយស្រួលធ្វើជាងគេ ដោយគ្រាន់តែយក ដើមឫស្សីមួយ កង់ៗ ហើយកាត់ថ្នាំងចេញទាំងសងខាង និងតម្រឹមមាត់វាឱ្យស្មើជា ការស្រេច ។ អ្នកលេងមានពីរ នាក់ប្រុសក៏បាន ស្រីក៏បាន ហើយគេលេងនៅពេល យប់ ក្នុង ចន្លោះខែកញ្ញា និង ខែតុលា ព្រោះខែ នេះស្រូវស្រាលដូចជាស្រូវ កាញ់ជៃ ស្រូវក្រែង និងស្រូវកាវែតទុំអស់ហើយ ។ បើលេងខុស ពីខែ នេះ ចាស់ៗមានជំនឿថា វានឹងមានគ្រោះថ្នាក់ដោយសារខ្លាខាំ ។ បទគេលេងទិងទូត មានពីរ ប្រភេទគឺបទឃឹត និងបទលឿន ។



## ១៥.១.កាណំ កាណុង កាន តាប៉ះ ទិងទូត / ត្រណមភ្លេងទិងទូត

ខ ពូ តាប៉ះ វ៉ាំងវ៉ាំង ខៃ រកតីស លូ ខៃ សប់ ញូន ខៃ ណោះ ឃឺ ខៃ ឡាក់ ប៊ិក ណាំង សារ ប៉ិច កាប់ សា ពៀឡឹគ ទឹល នីណោះ អ៊ែ កា ប៉រ់ ឡាង៉ា ហះ ពៀឡឹគ ។ ពៀឡឹគ កា អន់ ឡាង៉ា កា ប៊ិក ម៉ោញ កាន់តូត ។ ឡៃង ណោះ ប៊ិក ចាចឹប អន់តូត ឡាង៉ា តាលុះ សឹគ ឡាង៉ា ធ្វើ ទិ ប៉ឿះ ។ ពៀឡឹគ អន់ ឡាង៉ា ណាវ្គ កា ប៊ិក អ្ហូ ចៃ អ្យក់ អ៊ែ ខំ អង់អ្វែ ទូញ កាវ ឡាង៉ា ណោះ ទឹល តាប់ ម៉ាំង ។ ប៉ាត់ កាម៉ាំង ប៊ិក ណោះ កា កាប់ សា ណាង ពៀឡឹគ ។

ប៉ាត់ អន់តឹគ ម៉ី ពៀឡឹគ សិច តាម័ផោត ជៀង ប៊ិក អៃត លូ តាប៉ះ ទិងទូត អន់ ប៊ិក កាតាប័ តុត វ៉ត់ អន់ទ្រួល កេះណោះ អ៊ែ ប៉ាន់តោ ប៊ិក

មូលហេតុ គេលេងទិងទូត តែក្នុងខែ កញ្ញា -តុលា ជាខែ ដែលខ្លាប្រើល្បិចកល សុំលូនាង ពៀឡឹគ ហើយនាងពៀឡឹគក៏ឱ្យលូទៅខ្លានោះមួយកច្ចប់ ។ ពេលបានលូររួចមកខ្លួនហើយ ខ្លាទំលុះ កញ្ចប់នោះនឹងក្រចករបស់វា ធ្វើឱ្យលូកំពប់អស់ ។ ឃើញដូចនោះនាងពៀឡឹគក៏ឱ្យលូទៅខ្លាម្តង ទៀត តែខ្លាមិនព្រមទទួលយក វាសុខចិត្តអង្គុយរើសគ្រាប់លូតាំងពីព្រឹករហូតដល់ថ្ងៃលិច ។ បន្ទាប់ មកខ្លាក៏ខាំសម្លាប់នាងពៀឡឹគតែម្តងទៅ ។ ក្រោយមក សត្វខ្លាត្រូវបានបងនាងពៀឡឹគឈ្មោះតាម័ ផោតសម្លាប់តែមុននឹងសម្លាប់ តាម័ផោតបានប្រើល្បិចឱ្យខ្លាផឹកស្រា និងលេងភ្លេងទិងទូតជាមួយ គ្នា ហើយរាំសប្បាយអស់ចិត្តសិន ។

## ១៥.២.កាន យរ ទិងទូត / ការប្រើប្រាស់ទិងទូត

ពូ តាប៉ះ ទឹង ទូត អា ត្រត់ តងកាន ប៉ាណួស ២ ដូវ មួត តាតាម័ រ៉ូះ កា ដាត់ មួត សាណាដី កាដាត់ មួត សាស្វា កា ដាត់ ។ ពូ តាប៉ះ ទឹង ទូត ឃឺ ប៊ុច កា រ៉ត់ សើម ខង រកតឹស លូ សប់ ណោះ មួត កាំឡាំង ស្រុក អន់ខ្ញុំ សង់ ពៀ ណាវ កេះ សួន អៀង ពូ តាប៉ះ មង កាម៉ាំង ។

ការលេងទិងទូតនេះ ត្រូវការមនុស្ស២នាក់ គឺពួកកំលោះក្រមុំក៏បាន ចាស់ៗវ័យកណ្តាលក៏បាន ឬពួកក្មេងៗក៏បានដែរ ។ គេលេងភ្លេងទិងទូតនេះ ដើម្បីកំសាន្តអារម្មណ៍ និងបង្ហាញពីភាពត្រេកអរ ព្រោះ ចន្លោះខែ កញ្ញា-តុលា នេះ អ្នកភូមិបានស្រូវថ្មីហូបទាំងអស់គ្នា ហើយភាគច្រើនគេលេងនៅពេលយប់ ។



## ១៦. រ៉ាទឹុះ / ស្នែខ

**រ៉ាវើុះ** អា ក្រាគ់ សើគ ពែ ប្រ៉ែគ័ សាំរ៉ាប់ ខ្លោម ផះ អន់ឌ្មែ សឹត ឡឹង ទ្រុះ ប៉្លះ តាកូះ៍ ចំបាំង សឹត ឡឹង ក្ញិគ័ រ៉ាវេះ ព្រី ។ ប៉ានឹរ អ៊ែ សាដាល់ ខាក់ ហះកា អ្ូ វ៉ែគ់ អ្ូ វែ ឡាក់កា យឿង វ៉ែគ់ អន់ ទៀគ ៗ ណោះ អ៊ុះ ។

**ស្នែង**ជាឧបករណ៍ភ្លេងមួយដែរ ដែលគេបង្កើតឡើងសម្រាប់ផ្លុំពេលណាគេមកពីធ្វើចម្បាំង ឬមកពីទាក់ដំរីព្រៃ ។ វាមានសំឡេងឮខ្លាំងយ៉ាងកងរំពង តែមិនពីរោះដូចភ្លេងផ្សេងៗនោះទេ ។



## ១៦.១.កាណាគ័ ពូ អ្យក់ ប្រ៉ែគ័ រ៉ាវើុះ / ធនធានដែលគេយកមកធ្វើស្នែង

រ៉ាវើុះ ពូ ប្រ៉ែគ័ លូ អង់គែ កាប៉ូវ ផះ ប៉ាញ៉ូ តាម័ ភឿ ដាគ់ កាចាប័ លូ ដាគ់ ឡាម៉ែគ់ ចាំង អន់ អ៊ែ ដាគ់ ជៀល ប្លឹច ៗ ។ អំប្យិត អ៊ែ ពូ ប្រ៉ែគ័ លូ សាប៉ាន័ ឡាក់ ចារ សាំរ៉ាប់ ខ្លោម អន់ អ៊ែ តេះ ។

**ស្នែង**ជាឧបករណ៍ភ្លេង ដែលគេធ្វើអំពីស្នែងក្របី កំពុងពេញវ័យ ដើម្បីឱ្យវាជាប់ល្អ និងងាយស្រួលចាំង និងខាត់ឱ្យវាស្អាតរលោង ។ អណ្តាតវាគេធ្វើពីស្ពាន់ ដែលជាកន្លែងគេផ្លុំឱ្យឮសំឡេង ។

## ១៦.២.កាន យរ វ៉ាវ៉ើះ / ការប្រើប្រាស់ស្នែង

វ៉ាវ៉ើះ អា មួត ក្រាក់ ស្រុក ក្រាក់ តេះ អូ អន់ ពឿ ខ្លោម ឡិគ័ឡាគ័ តាម ប៊ិច តាម ចៃ អុះ ។ មួត ក្រាក់ ខ្លោម អ៊ែ ទី ព្យេវ នៃវ សាំខាន់ ៗ ឡាក់កា កាន់តេះ អា ៖

**១.ខ ពូ ខ្លោម សឹត ឡឹង តាកួះ ចំបាំង :** សើគ ពៃ ផា កាតាំង មួត សឹត ឡឹង តាកួះ ចំបាំង ខ្លោម វ៉ាវ៉ើះ ឡុង ៗ ឡុង ៗ កេះ ទី ណើ ផា មួត ឡាំ ប៉្លះ ឡាំ តាកួះ ណោះ ទី ប៉ាន់តៅ ទី វ៉ុប មួត តាមឹរ អៀង ដូវ ហង ។

**២.ខ ពូ ខ្លោម សឹត ឡឹង ក្ងីគ័ វ៉ាវេះ ព្រី :** សើគ ពៃ ផានៃវ ពូ សឹត ឡឹង ក្ងិគ័ វ៉ាវេះ ព្រី អ្លុ ប្រ៉េគ័ ទី អន់ឌ៉ៃ ហោក វ៉ែគ់ ខាក់ ។ ណោះ ហង ប៉ាគ់ អន់ឌ៉ៃ សឹត ចឹង ក្យាម័ ឡាំប៉ាត ស្រុក កេះ អន់ឌ៉ៃ ខ្លោម វ៉ាវ៉ើះ អន់ កាំឡាំង ស្រុក តេះ អ្លុ អន់តគ់ ផា អន់ឌ៉ៃ ចាក ក្ងិគ័ វ៉ាវេះ ណោះ អ្លុ ប្រ៉េគ័ ទី អូ ហ្វាច ដាវ់ អុះ ។

ស្នែងនេះ ចាស់ៗ ឬមេកន្ទ្រាញភូមិ មិនអនុញ្ញាតឱ្យនរណាម្នាក់ ផ្លុំផ្តេសផ្តាស់បានឡើយ ។ មេកន្ទ្រាញភូមិផ្លុំវាបានតែក្នុងកម្មវិធីដូចខាងក្រោម ៖

**១.អត្ថន័យផ្លុំមកពីធ្វើចម្បាំងៈ** ពីដើមបើឮសំឡេងស្នែងយ៉ាងកងរំពងហើយនោះ មានន័យថាអ្នកទៅច្បាំង បានយកឈ្នះលើមាសត្រូវ ហើយបានចាប់មកធ្វើជាឈ្លើយសឹកទៀតផង ។

**២.អត្ថន័យផ្លុំពេលមកពីទាក់ដំរីព្រៃះ** ពីដើម ពេលណាគេទាក់ដំរីព្រៃបាន ពួកគេត្រេកអរយ៉ាងខ្លាំង ។ ហើយពេលគេត្រលប់ជិតដល់ភូមិកាលណា គេតែងតែផ្លុំស្នែង ជាសញ្ញាមួយប្រាប់ឱ្យអ្នកភូមិដឹងថា ពួកគេ (អ្នកទៅទាក់ដំរី) ទាក់ដំរីបាន មិនមែនចំណាយពេលឥតប្រយោជន៏នោះទេ ។

## ១៧. អន់ហ្វៃង / ស្នែងតាន់

**អន់ហ្វៃង** ឃី យឿង ពូ ប្រ៉ត័ លូ អង់កែ កាប៉ូវ ដេល អ៊ែ ទី ត្រោម ដឹង គែង គុល លូ ទី អំប៉្រិត ពឹង អន់តិត័ ពូ ខ្លោម អ៊ែ ដឹង កាណុង កាន អៃត សង់ តីស៧ កាណុង ស្រុក ។ ផា ពូ ខ្លោម ពូ ត្រត់ ប៊ិត ប៉ាអប់ ៧ គុល អង់កែ លូ តាប៉ាង តី ។

ស្នែង តាន់ ជាឧបករណ៍ភ្លេងដែលគេធ្វើពីស្នែងក្របី និងមានអណ្តាតដូចស្នែងធម្មតាដែរ តែវាតាន់នៅផ្នែកខាងចុង ។ គេផ្លុំវាតែក្នុងពិធីសែនភូមិធំៗតែប៉ុណ្ណោះ ។ ពេលគេផ្លុំ គេប្រើបាតដៃសម្រាប់បិទបើកគល់ស្នែង ។

### ១៧.១.កាន យរ អន់ហ្វៃង/ ការប្រើប្រាស់ស្នែងតាន់

អន់ហ្វៃង អា មួត ក្រាត់ តាំងកង់ ខ្លោម កាណុង កាន អៃត សង់ គីត៧ ឡាក់កាអៃត ហាវ រ៉ោង កោះ កាប៉ូវ ១ លើ ២ កេះណោះ ពូ ខ្លោម ដឹង ផះ កាម៉ាំង រ៉ាំងរ៉ាង ពូ បាបន់ អន់ កាប៉ូវ កា ប្រ៉ះ ព្រី ប្រ៉ះ ប៉ានឹម ផះ ណោះ ពូ ចំ គួង យុ **គួង ច្វារ័** ។

ស្នែងតាន់នេះ ចាស់ៗ ផ្លុំក្នុងពិធីភូមិដែលមានលក្ខណៈទ្រុងទ្រាយធំដូចជា ពិធីឡើងរោងភូមិថ្មី ដោយមានកាប់ក្របី១ក្បាល ឬ ២ក្បាល ហើយគេផ្លុំវានៅពេលយប់ ស្របពេលដែលគេថ្វាយក្របីទៅអារក្សអ្នកតាម្ចាស់ទឹកម្ចាស់ដី និងស្របពេលគេវាយគងបទ **គួងច្វារ័** ផងដែរ ។

## ១៧.២.៩ ពូ ខ្លោម អន់ហ្មែង / អត្ថន័យនៃការផ្លុំស្នែង

ណើ ពូ ខ្លោម អន់ហ្មែង ឃី ប៉ិច អន់ ប្រ៉ះ ព្រី ប៉ានឹម ឡាក់ តាំងឡា ព្រី ទៀក ប្រ៉ះ អ្លួ អន់តគ់ អ្លួ កាតាំង ឡឹង កាន ពូ អៃត សៃន ស្រុក អា ហង លូ ប៉ិច កា អន់ កាន សាណុក សាវ៉ាក កា កាំឡាំង ស្រុក ។

អត្ថន័យ គេផ្លុំស្នែងតាន់ គឺចង់ឱ្យអារក្សអ្នកតា ព្រៃភ្នំ ម្ចាស់ទឹកម្ចាស់ដី ដឹងពីពិធីសែនភូមិនេះ និងផ្តល់សេចក្តីសុខដល់ប្រជាជនក្នុងភូមិ ។

## ១៨. រ៉ាយ៉ាត់ / រ៉ាយ៉ាត់

**រ៉ាយ៉ាត់** ឃី ឃឿង ពូ ខ្លោម ឡាក់ អ្វូ ទី យុ អញ់សៃ៊ សាំរ៉ាប់ អន់ ពិន ហៀន ពួយ អ៊ុះ ពឿ ខ្លោម អ៊ែ ត្រគ់ ប្រ៉ឝ័ យុ អញ់សៃ៊ ឡាកោ ទៅ តាម ពុត ប៊ុច ។

**រ៉ាយ៉ាត់** វាជាឧបរណ៏ភ្លេងដែល គ្មានលំនាំបទសម្រាប់ឱ្យយើងរៀនតាមនោះទេ ដូចនេះបើអ្នកណាផ្លុំវា អ្នកនោះ ត្រូវនឹករកទំនុកបទ ដោយខ្លួនឯងតាមតែនឹកឃើញ ។



### ១៨.១.កាណាឝ័ ពូ អ្យក់ ប្រ៉ឝ័ រ៉ាយ៉ាត់ / ធនធានដែលគេយកមកធ្វើរ៉ាយ៉ាត់

រ៉ាយ៉ាត់ អា ពូ ប្រ៉ឝ័ អ៊ែ លូ ប៉ាអ្វូ លើ សាលៀវ ១ អង់រ៉ាន គម អង់កោស ១ ប៉ែង កេះណោះ តាំប្រើល អន់ តាលុះ ទី ត្រោម ពឹង អន់តិឝ័ សាំរ៉ាប់ ខ្លោម ។

រ៉ាយ៉ាត់ ជាកំណាត់ឫស្សីមួយកំណាត់ដែលគេទុកថ្នាំងមួយចំហៀងសម្រាប់ចោះរន្ធតូចចំកណ្តាលដើម្បីផ្លុំកើតជាសំឡេង ។

## ១៨.២.កាន យរ រ៉ាយ៉ាត់ / ការប្រើប្រាស់ភ្លេងរ៉ាយ៉ាត់

ពូ សើគ ពែ ពូ ខ្លោម រ៉ាយ៉ាត់ អា ផះ ពូ អ៊ែ្វ ក្យាត់ ម៉ិរ អ៊ែ្វ ១ ដូវ ១ ខៃន អូទី គួប រ៉ៈ សារ  កាតាំង ដឹង ប៉ានីរ អ្យាំ សៃម លូ ខ្យាល ប៉ាយ៉ើល ហ្លា អ្យិត ហ្លា អ៊្លឹង ។ ពូ ខ្លោម ក្រាន់ កា ប៉ារ៉ែគ ពុត ពៀក ភឿ ប៉ិច កា អង់រ៉ើង កា អ៊ែ្វ ១ ដូវ ។

ចាស់បុរាណ ផ្លុំភ្លេងនេះនៅពេលណាដែលគេនៅចំការតែម្នាក់ឯង គ្មានដៃគូ វាចារឆ្លងឆ្លើយសម្តីជាមួយ ក្រៅអំពីសំឡេងសត្វព្រៃយំចេចចាច និងសំឡេងខ្យល់បក់ស្រោល១ ធ្វើឱ្យស្លឹករុក្ខជាតិទាំងពួងកំរើករេរាំរវិច១ ។  ដូចនេះគេផ្លុំត្រលៀកបង្កើតសំឡេង តាមសំឡេងវាយោ  ដើម្បីកំដរបរិយាកាសស្ងប់ស្ងាត់ កណ្តោចកណ្តែង  ។



Prepared for first online distribution in July 2014 by

អង្គការសហការអន្តរជាតិកម្ពុជា

International Cooperation Cambodia

P.O. Box 612

Phnom Penh, Cambodia

Tel: 092-469-934 / 075-974-029

http://www.icc.org.kh

ams.rtk.ibcde@icc.org.kh

This work is licensed under the Creative Commons Attribution-ShareAlike 4.0 International License. To view a copy of this license, visit http://creativecommons.org/licenses/by-sa/4.0/.

**You are free to:**

**Share** — copy and redistribute the material in any medium or format
**Adapt** — remix, transform, and build upon the material
for any purpose, even commercially.
The licensor cannot revoke these freedoms as long as you follow the license terms.

**Under the following terms:**

**Attribution** — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

**ShareAlike** — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original.
**No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.**